ABA BANK
NATIONAL BANK OF CANADA GROUP

# របាយការណ៍ប្រចាំត្រីមាសទី២

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

## ធនាគារវឌ្ឍនៈអាស៊ី ចំកាត់

(ធនាគារ ABA)

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២០ | ៣១ ខែធ្នូ ឆ្នាំ២០១៩ |
|---|---:|---:|
| ទ្រព្យសកម្មសរុប | ២០.៣៦៦.៦៥៥ | ១៧.៩០៩.១៧០ |
| បំណុលសរុប | ១៧.៥៧៥.៤៩៩ | ១៥.៨៨៦.៤២១ |
| មូលធនសរុប | ២.៧៩១.១៥៦ | ២.០២២.៧៤៩ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | **ត្រីមាសទី២ ឆ្នាំ២០២០** | **ត្រីមាសទី២ ឆ្នាំ២០១៩** |
| ចំណូលសរុប | ៣៧៧.៤៣៧ | ២៨៨.៤២២ |
| ប្រាក់ចំណេញមុនបង់ពន្ធ | ១៦៧.៧៣១ | ១២៧.៦០៦ |
| ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | ១៣០.៨៣០ | ១០១.៤៨៧ |
| ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ | ១៣៧.៤៤១ | ១០៩.៨៧១ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី២ ឆ្នាំ២០២០** | **៣១ ខែធ្នូ ឆ្នាំ២០១៩** |
| អនុបាតសោធនភាព | ២១,០៨ | ១៩,៩៤ |
| អនុបាតបំណុលធៀបនឹងមូលធន | ៦២៩,៦៩ | ៧៨៥,៣៩ |
| អនុបាតសន្ទនីយភាព | ១៨១,៦២ | ១៦២,៣២ |
| អនុបាតឥណទានមិនដំណើរការ | ០,៩០ | ០,៧០ |
| អនុបាតបញ្ញើធៀបនឹងឥណទាន | ៨១,៨៦ | ៨១,៤២ |
| **អនុបាតផលចំណេញ (%)** | **ត្រីមាសទី២ ឆ្នាំ២០២០** | **ត្រីមាសទី២ ឆ្នាំ២០១៩** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA) [១] | ០,៧០ | ០,៨០ |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE) [១] | ៥,០៦ | ៧,៦៣ |
| អនុបាតលទ្ធភាពបង់ការប្រាក់ [១] | ៣៧២,១២ | ៣៥៩,០៥ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | គ្មាន | គ្មាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនមាន) | គ្មាន | គ្មាន |

[១] អនុបាតទាំងនេះមិនមែនជាអនុបាតប្រចាំឆ្នាំនោះទេ ហើយត្រូវបានគណនាដោយប្រើតួលេខចំណេញ ឬខាត រយៈពេល ៣ខែ ចាប់ពីថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា នៃឆ្នាំនីមួយៗ។

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

## ទ្រព្យសកម្មសរុប
គិតជាលានរៀល

+១៣,៧% ▲
ពីឆ្នាំ២០១៩

**២០.៣៦៦.៦៥៥**
ត្រីមាសទី២ ឆ្នាំ២០២០

**១៧.៩០៩.១៧០**
ឆ្នាំ២០១៩

## បំណុលសរុប
គិតជាលានរៀល

+១០,៦% ▲
ពីឆ្នាំ២០១៩

**១៧.៥៧៥.៤៩៩**
ត្រីមាសទី២ ឆ្នាំ២០២០

**១៥.៨៨៦.៤២១**
ឆ្នាំ២០១៩

## មូលធនសរុប
គិតជាលានរៀល

+៣៨% ▲
ពីឆ្នាំ២០១៩

**២.៧៩១.១៥៦**
ត្រីមាសទី២ ឆ្នាំ២០២០

**២.០២២.៧៤៩**
ឆ្នាំ២០១៩

## លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ
គិតជាលានរៀល

+២៥,១% ▲
ពីត្រីមាសទី២ ឆ្នាំ២០១៩

**១៣៧.៤៤១**
ត្រីមាសទី២ ឆ្នាំ២០២០

**១០៩.៨៧១**
ត្រីមាសទី២ ឆ្នាំ២០១៩

## អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម
គិតជាភាគរយ

-១០ BPS (ឯកតាមូលដ្ឋាន)
ពីត្រីមាសទី២ ឆ្នាំ២០១៩

**០,៧០**
ត្រីមាសទី២ ឆ្នាំ២០២០

**០,៨០**
ត្រីមាសទី២ ឆ្នាំ២០១៩

## អនុបាតចំណេញធៀបនឹងមូលធនមធ្យម
គិតជាភាគរយ

-២៥៧ BPS (ឯកតាមូលដ្ឋាន)
ពីត្រីមាសទី២ ឆ្នាំ២០១៩

**៥,០៦**
ត្រីមាសទី២ ឆ្នាំ២០២០

**៨,៣៥**
ត្រីមាសទី២ ឆ្នាំ២០១៩

# សមាសភាពក្រុមប្រឹក្សាភិបាល



**Yves Jacquot**
ប្រធានក្រុមប្រឹក្សាភិបាល



**Dominic Jacques**
អភិបាលមិនប្រតិបត្តិ



**Madi Akmambet**
អភិបាលប្រតិបត្តិ



**Martin Ouellet**
អភិបាលមិនប្រតិបត្តិ



**Christian St-Arnaud**
អភិបាលមិនប្រតិបត្តិ



**Guy Quaden**
អភិបាលឯករាជ្យ



**Henri Calvet**
អភិបាលឯករាជ្យ



**Etienne Chenevier**
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព ខ្ញុំបាទសូមអនុញ្ញាតអធិប្បាយក្នុងរបាយការណ៍នេះ អំពីលទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ABA ក្នុងត្រីមាសទីពីរ ឆ្នាំ ២០២០ ដោយអនុវត្តតាមលក្ខខណ្ឌតម្រូវនានារបស់គណៈកម្មការមូលបត្រកម្ពុជា (SECC)។

ធុរកិច្ចកម្ពុជាបន្តរងឥទ្ធិពលពីការធ្លាក់ចុះនៃសេដ្ឋកិច្ច ដោយសារការរីករាលដាលនៃវីរុសកូវីដ-១៩ ទូទាំងពិភពលោក។ ខេត្តសៀមរាប និងខេត្តព្រះសីហនុ ដែលមួយផ្នែកធំពឹងផ្អែកលើវិស័យទេសចរណ៍ បានទទួលរងផលប៉ះពាល់យ៉ាងខ្លាំង។ សកម្មភាពពាណិជ្ជកម្ម នៅខេត្តបាត់ដំបង និងតំបន់ជុំវិញ បានធ្លាក់ចុះយ៉ាងខ្លាំងដោយសារការបិទបណ្តាផ្សារនៅតាមច្រកព្រំដែនកម្ពុជា-ថៃ ខណៈដែលវិស័យកាត់ដេរ ដែលភាគច្រើនមានមូលដ្ឋាននៅរាជធានីភ្នំពេញ និងខេត្តកណ្តាលបានជួបនឹងឱនភាពធ្ងន់ធ្ងរ។

ពាក់ព័ន្ធនឹងបញ្ហានេះ ធនាគារ ABA បន្តរៀបចំកម្ចីឡើងវិញដល់អតិថិជនក្រោមគោលនយោបាយរៀបចំកម្ចីឡើងវិញ ដែលបានអនុម័តតាមសារាចរណែនាំរបស់ធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០។ ក្នុងឆមាសទី២ ឆ្នាំ២០២០ ធនាគារបានរៀបចំឡើងវិញចំនួន ៨.៥០៩កម្ចី ដែលមានតម្លៃទឹកប្រាក់ ៤៣៥,៧លានដុល្លារអាមេរិក។ អត្រានៃកម្ចីដែលបានរៀបចំឡើងវិញនៅក្នុងផលបត្រសរុប នៅមានកម្រិតទាប និងមានចំនួន ១៦,៣%។ ស្របពេលជាមួយគ្នានេះ ABA ពិចារណារៀបចំកម្ចីឡើងវិញប្រកបដោយគុណភាពខ្ពស់ ដោយ ៩២%ក្នុងចំណោមនោះបានស្នើសុំ រយៈពេលអនុគ្រោះលើការបង់ប្រាក់ដើម ដោយបន្តបង់តែការប្រាក់។ ការអនុវត្តបែបនេះ អនុញ្ញាតឲ្យធនាគារព្យាករណ៍លើប្រភពចំណូល និងធ្វើផែនការសកម្មភាពសម្រាប់រយៈពេលមួយឆ្នាំពេញ។ ធនាគារ ABA នឹងបន្តជួយដល់ អតិថិជនកម្ចីដើម្បីជម្នះបញ្ហាអំឡុងពេលកំពុងជួបឧបសគ្គតាមរយៈគោលនយោបាយរៀបចំកម្ចីឡើងវិញ។

ធនាគារបានយល់យ៉ាងច្បាស់នូវតួនាទីសំខាន់នៃវិស័យហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសជាតិ ហើយក្រៅពីការរៀបចំកម្ចីឡើងវិញ ធនាគារក៏បន្តផ្តល់កម្ចីដល់អតិថិជនចាស់ថ្មីបន្ថែមទៀត។ ត្រឹមអំឡុងឆមាសទី២ ឥណទានអាជីវកម្មចំនួន ៦.១១៤ ដែលមានទឹកប្រាក់ ៣២២,៥ត្រូវបានបញ្ចេញជូនអតិថិជន។ លទ្ធផលនេះ បានបង្កើនផលបត្រកម្ចីដុលប្រមាណ ៤,២% លើផលបត្រកម្ចី ៣,១ប៊ីលានដុល្លារអាមេរិក គិតចាប់ពីត្រីមាសទីមួយដល់ត្រីមាសទីពីរ។

ដើម្បីបន្ថែមការគាំទ្រដល់អាជីវកម្មដែលរងផលប៉ះពាល់ទូទាំងប្រទេស ABA បានចូលរួមគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ឆ្នាំ២០២០ (SCFS) ក្រោមគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងគោលបំណងផ្តល់ឥណទានមានការប្រាក់ទាប ដើម្បីជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេស។ ក្រោមគម្រោងសហហិរញ្ញប្បទាននេះ ធនាគារ ABA បានផ្តល់កម្ចីសម្រាប់ទុនបង្វិល និងចំណាយមូលធន ជាមួយអត្រា ការប្រាក់ពិសេស ៧% ក្នុងមួយឆ្នាំជាមួយរយៈពេលឥណទាន ៧ឆ្នាំ។

ផ្នែកមូលនិធិ ធនាគារ ABA បន្តសាងឡើងនូវស្ថិរភាពផលបត្របញ្ញើរបស់ខ្លួន ដែលបានកើនឡើងក្នុងត្រីមាសទីពីរលើ មូលនិធិ ៣,៨ប៊ីលានដុល្លារអាមេរិក ដែលមានកំណើន ៨,៦% ធៀបនឹងត្រីមាសទីមួយសម្រាប់ឆ្នាំ២០២០។ អតិថិជនកាន់តែច្រើនឡើងៗ បន្តជ្រើសយក ABA ធ្វើជាដៃគូបម្រើសេវាធនាគារដល់ពួកគេ។ ជាលទ្ធផល មូលដ្ឋានអតិថិជន របស់ធនាគារនៅក្នុងត្រីមាសទីពីរ កើនបាន ១៥% ហើយចំនួនអតិថិជន ABA បានឡើងហួស ១លាន។

សំដៅលើសូចនាករសមត្ថភាពហិរញ្ញវត្ថុរបស់ធនាគារនៅក្នុងត្រីមាសទីពីរប្រចាំឆ្នាំយើងបន្តទទួលបានកំណើនប្រកបដោយស្ថិរភាព។

គិតត្រឹមដំណាច់ត្រីមាសទីពីរ ឆ្នាំ២០២០ ទ្រព្យសកម្មសរុបកើនបាន ៨,៧% ធៀបនឹងត្រីមាសទីមួយ និងសមមូល ៥ប៊ីលានដុល្លារអាមេរិក។ មូលធនភាគហ៊ុនិករបស់ធនាគារកើនឡើងដល់ ៦៨២លានដុល្លារអាមេរិក ក្នុងការិយបរិច្ឆេទនៃរបាយការណ៍។ ធនាគារ មានសមត្ថភាពអាចរក្សាបានផលចំណេញសុទ្ធ ៣២,១លានដុល្លារអាមេរិក ក្នុងត្រីមាសទីពីរ ឆ្នាំ២០២០ ខណៈប្រាក់ចំណេញសុទ្ធតាំងពីដើមឆ្នាំកើនដល់ ៦៥,៦លានដុល្លារអាមេរិក។

ធនាគារ ក៏បន្តវិនិយោគលើធនាគារឌីជីថលរបស់ខ្លួន។ ការណ៍នេះ ធ្វើឲ្យប្រព័ន្ធទូទាត់អនឡាញ PayWay របស់ ABA ត្រូវបានជ្រើសរើសសម្រាប់ការប្រមូលការទូទាត់នៅលើថ្នាលបច្ចេកវិទ្យាព័ត៌មាន Single Portal សម្រាប់ការចុះបញ្ជីអាជីវកម្មអនឡាញដែលបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានកិច្ចសហប្រតិបត្តិការជាមួយក្រសួង និងទីភ្នាក់ងាររដ្ឋាភិបាលជាច្រើនផ្សេងទៀត។

ធនាគារតាមទូរស័ព្ទដៃ ABA Mobile ទទួលបានការពង្រឹងបន្ថែមជាច្រើន ដូចជាសេវាផ្ទេរប្រាក់ទៅធនាគារក្នុងស្រុកមុខងារគ្រប់គ្រងកាតធនាគារ និងមុខងារផ្ទេរប្រាក់ឆ្លងប្រទេស និងក្នុងប្រទេសភ្លាមៗជាមួយ Visa Direct។

ក្នុងទិដ្ឋភាពទូទៅ ABA បន្តអនុវត្តយុទ្ធសាស្ត្រធុរកិច្ចរបស់ខ្លួន ដោយផ្តោតការយកចិត្តទុកដាក់លើផលិតផលហិរញ្ញវត្ថុឌីជីថល ក៏ដូចជាឥណទានប្រកបដោយផលិតភាពដល់អាជីវកម្មនៅក្នុងវិស័យដែលបម្រើដល់សេដ្ឋកិច្ចពិតប្រាកដ។ ធនាគារ អនុវត្តវប្បធម៌គ្រប់គ្រងហានិភ័យដ៏រឹងមាំដែលពង្រឹងដោយមុខងារសវនកម្ម និងប្រតិបត្តិតាមទូទាំងធុរកិច្ចរបស់ខ្លួន។

ក្នុងនាមជាធនាគារពាណិជ្ជកម្ពុជាទីមួយ ដែលបោះផ្សាយសញ្ញាប័ណ្ណសាជីវកម្មក្នុងចំនួនទឹកប្រាក់សរុប ៨៤,៨ប៊ីលានរៀល ABA ក៏ដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍទីផ្សារមូលបត្រ និងលើកកម្ពស់ប្រាក់រៀល។

ដោយសង្កេតលើការណ៍នេះ និងសមិទ្ធផលសម្រេចបានផ្សេងទៀតរបស់ធនាគារ ទស្សនាវដ្ដីអន្តរជាតិ Euromoney បានផ្ដល់កិត្តិយសជូន ABA ជាមួយពានរង្វាន់ "ធនាគារឆ្នើមជាងគេនៅកម្ពុជា ឆ្នាំ២០២០" ដែលត្រូវបានចេញផ្សាយក្នុងខែកក្កដា ឆ្នាំ២០២០។

ក្រុមប្រឹក្សាភិបាល នឹងបន្តដើរតួនាទីក្នុងការពិនិត្យមើលការប្រតិបត្តិនូវយុទ្ធសាស្ត្ររបស់ធនាគារដោយផ្អែកលើការអនុវត្តល្អបំផុត និងស្តង់ដារនានា។ សម្រាប់ហេតុផលនេះ ក្រុមប្រឹក្សាភិបាលមានសមត្ថភាពពេញលេញដែលសមាជិករបស់ខ្លួនដែលមានសាវតារ និងជំនាញរឹងមាំខាងហិរញ្ញវត្ថុ និងអភិបាលកិច្ចសាជីវកម្ម។

តំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមអរគុណចំពោះគណៈប្រតិបត្តិនៃធនាគារ ABA សម្រាប់ភាពជាអ្នកដឹកនាំ និងការប្ដេជ្ញាចិត្តរបស់ពួកគេ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះធនាគារជាតិនៃកម្ពុជា និងគណៈកម្មការមូលបត្រកម្ពុជា (SECC) សម្រាប់មគ្គទេសក៍ និងការគាំទ្រ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណចំពោះអតិថិជនទាំងអស់ និងភាគីពាក់ព័ន្ធនានាសម្រាប់ទំនុកចិត្តរបស់ពួកគេមកលើធនាគារ ABA គ្រប់ពេលវេលា។

ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០

លោក **Yves Jacquot**
ប្រធានក្រុមប្រឹក្សាភិបាល

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប II

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប III

សមាសភាពក្រុមប្រឹក្សាភិបាល IV

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល V

**ផ្នែកទី ១. ព័ត៌មានទូទៅពាក់ព័ន្ធបុគ្គលចុះបញ្ជីលក់មូលបត្រ** ២

ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ៣

ខ. លក្ខណៈនៃធុរកិច្ច ៣

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ៤

**ផ្នែកទី ២. ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ៥

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក ៦

ខ. រចនាសម្ព័ន្ធចំណូល ៦

**ផ្នែកទី ៣. របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** ៧

**ផ្នែកទី ៤. ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ៩

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ១០

ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ១២

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ១៣

ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ១៣

ង. ផលប៉ះពាល់នៃអតិផរណា ១៣

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ១៣

ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ១៤

# ផ្នែកទី ១

## ព័ត៌មានទូទៅពាក់ព័ន្ធបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ |
| ជាអក្សរឡាតាំង | Advanced Bank of Asia Limited |
| លេខកូដស្តង់ដារ | KH ២០០០០៩១៩៨៦ |
| ទីស្នាក់ការ | អគារលេខ១៤១, ១៤៦, ១៤៨ និង១៤៨ អា បេ សេ ដេ វិថីព្រះសីហនុ និងអគារលេខ ១៥ និង ១៥៣ អា បេ សេ ផ្លូវលេខ ២៧៨ សង្កាត់ បឹងកេងកង ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | (+៨៥៥) ២៣ ២២៥ ៣៣៣ |
| លេខទូរសារ | (+៨៥៥) ២៣ ២១៦ ៣៣៣ |
| គេហទំព័រ | www.ababank.com |
| អ៊ីមែល | info@ababank.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១០៥៩៣ ចុះថ្ងៃទី២៩ ធ្នូ ២០១០ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | B១៤ ចេញដោយធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី២៩ វិច្ឆិកា ២០១៩ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៥៥/១៩ គ.ម.ក. ចុះថ្ងៃទី០៧ សីហា ២០១៩ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Askhat Azhikhanov |

## ខ. លក្ខណៈនៃធុរកិច្ច

ធនាគារ ABA គឺជាគ្រឹះស្ថានហិរញ្ញវត្ថុឯកជនឈានមុខមួយរបស់កម្ពុជា (សហគ្រាសឯកជន) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៦ មានឈ្មោះថា ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់។ ឆ្លងកាត់ការអភិវឌ្ឍនិងកំណើនជាង ២០ឆ្នាំកន្លងមកនេះ ABA បានពង្រឹងជំហររបស់ខ្លួនយ៉ាងរឹងមាំក្នុងទីផ្សារ និងក្លាយជាធនាគារមួយក្នុងចំណោមធនាគារពាណិជ្ជកំពូលទាំងបី នៅក្នុងប្រទេស។ សព្វថ្ងៃនេះ ABA មានបម្រើសេវាជូនដល់បណ្តាអតិថិជនជាច្រើនដូចជា សហគ្រាសធុនតូចនិងមធ្យម, អាជីវកម្មខ្នាតតូច, និងរូបវន្តបុគ្គល។

ធនាគារ ABA គឺជាបុត្រសម្ពន្ធរបស់ធនាគារជាតិកាណាដា (www.nbc.ca) ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុមួយ មានទ្រព្យសកម្មជាង ២៣៤ ប៊ីលានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ និងមានបណ្តាញធនាគារសម្ព័ន្ធហិរញ្ញវត្ថុនៅទូទាំងពិភពលោក។ ក្នុងនាមជាភាគហ៊ុនិកមួយរបស់ធនាគារ ABA តាំងពីឆ្នាំ២០១៤ មក ធនាគារជាតិកាណាដាបានក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុអាមេរិកខាងជើងទីមួយ ដែលឈានជើងចូលវិស័យធនាគារនៅកម្ពុជា។ ដោយមានស្នាក់ការកណ្តាលស្ថិតនៅទីក្រុងម៉ុងរ៉េអាល់ ធនាគារជាតិកាណាដាបានពង្រីកសាខានៅស្ទើរតែគ្រប់ខេត្ត នៃប្រទេសជាមួយនឹងអតិថិជនក្នុងដៃ ២,៥លាននាក់។ នាមគ្រឹះស្ថានហិរញ្ញវត្ថុធំជាងគេលំដាប់ទី៦ ក្នុងប្រទេសកាណាដា និងនាំមុខគេនៅកេបិច ធនាគារជាតិកាណាដា ជាជម្រើសនៃបណ្តាសហគ្រាសធុនតូច និងមធ្យមនានានៅទីនោះ។

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ធនាគារ ABA គ្រប់គ្រងទ្រព្យសកម្មសរុប ៥,0 ប៊ីលានដុល្លារអាមេរិក និងបម្រើអតិថិជនជាង ១លាន ជាមួយបណ្តាញទូលំទូលាយ មានសាខា ៧៧ ម៉ាស៊ីនស្វ័យសេវាជាង ៦០០+ និងធនាគារអនឡាញ និងធនាគារតាមទូរស័ព្ទដ៏ទំនើប។

ធនាគារ ABA ទទួលបានចំណាត់ថ្នាក់លទ្ធភាពសង ‘B+’ រយៈពេលវែង ពីភ្នាក់ងារវាយតម្លៃឥណទាន Standard & Poor’s (S&P) Global Ratings។ កម្រិតឥណទានត្រូវបានដំឡើងពីកម្រិត 'B' ក្នុងខែធ្នូ ឆ្នាំ២០១៩។

# គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

នៅត្រីមាសទីពីរ ឆ្នាំ២០២០ ធនាគារ ABA ពង្រឹងបន្ថែមនូវប្រតិបត្តិការ និងស្ថានភាពទីផ្សាររបស់ខ្លួន។

## *ការអភិវឌ្ឍអាជីវកម្ម*

នៅខែមេសា ធនាគារបានចូលរួមគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ឆ្នាំ២០២០ (SCFS) ក្រោមគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងគោលបំណងផ្តល់ឥណទានមានការប្រាក់ទាប ដើម្បីជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេស។ ក្រោមគម្រោងសហហិរញ្ញប្បទាននេះ ធនាគារ ABA បានផ្តល់កម្ចីសម្រាប់ទុនបង្វិល និងចំណាយមូលធន ជាមួយអត្រា ការប្រាក់ពិសេស ៧% ក្នុងមួយឆ្នាំ ជាមួយរយៈពេលឥណទាន ៧ឆ្នាំ។

កម្មវិធីធនាគារតាមទូរស័ព្ទដៃ ABA Mobile ទទួលបានការពង្រឹងបន្ថែមជាច្រើន នៅត្រីមាសទីពីរ។ ឥឡូវនេះ អ្នកប្រើប្រាស់កម្មវិធី ABA Mobile អាចផ្ទេរប្រាក់ទៅធនាគារក្នុងស្រុកមុខងារគ្រប់គ្រងកាតធនាគារ និងមុខងារផ្ទេរប្រាក់ភ្លាមៗជាមួយ Visa Direct ទៅកាន់កាត Visa ណាមួយនៅកម្ពុជា និងកាត Visa ដែលចេញដោយធនាគារនៅប្រទេសថៃ វៀតណាម ឡាវ ភូមា ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូនេស៊ី និងហ្វីលីពីន។

ធនាគារ ក៏បន្តវិនិយោគលើសេវាកម្មពាណិជ្ជកម្មអេឡិកត្រូនិករបស់ខ្លួន គឺប្រព័ន្ធទូទាត់អនឡាញ PayWay ។ ការណ៍នេះ នៅខែមិថុនា ធនាគារ ABA ប្រកាសភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជាសម្រាប់សម្រួលការប្រមូលការទូទាត់នៅលើថ្នាលបច្ចេកវិទ្យាព័ត៌មាន Single Portal សម្រាប់ការចុះបញ្ជីអាជីវកម្មអនឡាញដែលបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានកិច្ចសហប្រតិបត្តិការជាមួយក្រសួង និងទីភ្នាក់ងាររដ្ឋាភិបាលជាច្រើនផ្សេងទៀត។ ដំណើរការដោយប្រព័ន្ធ PayWay ថ្នាលបច្ចេកវិទ្យាព័ត៌មាន Single Portal ជាដំណោះស្រាយរួមមួយសម្រាប់ការចុះបញ្ជីអាជីវកម្ម ការបង់ពន្ធ ថ្លៃសេវា និងការទូទាត់ផ្សេងៗរបស់ម្ចាស់អាជីវកម្ម និងអ្នកបង់ពន្ធ។ ដោយមានក្រសួងជាច្រើនបន្ថែមទៀត ម្ចាស់អាជីវកម្មកម្ពុជានឹងអាចធ្វើការទូទាត់ពាក់ព័ន្ធនឹងការចុះបញ្ជីអាជីវកម្មរបស់ពួកគេ និងប្រតិបត្តិការជាប្រាក់រៀលខ្មែរដោយប្រើ ABA PAY ដែលជាកម្មវិធីទូទាត់មិនប្រើសាច់ប្រាក់នៅក្នុងកម្មវិធី ABA Mobile ឬកាត Visa, Mastercard, ឬ UnionPay International របស់ពួកគេ។

## *ការទទួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គម*

ក្នុងរយៈពេលរបាយការណ៍នេះ ធនាគារបានផ្តល់ការយកចិត្តទុកដាក់យ៉ាងជិតស្និត និងធនធានរបស់ខ្លួនក្នុងការជួយអ្នកដែលរងគ្រោះដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ចដោយសារការរីករាលដាលនៃវីរុសកូវីដ-១៩។ ជាពិសេស ធនាគារ ABA បានរៀបចំយុទ្ធនាការរៃអង្គាសប្រាក់ក្នុងចំណោមអតិថិជនរបស់ខ្លួនដោយអនុញ្ញាតឲ្យពួកគេបរិច្ចាគចំនួនទឹកប្រាក់ណាមួយ ហើយធនាគារនឹងគុណទឹកប្រាក់នោះនឹងពីរ។ ដោយមានការឆ្លើយតបលើសលប់ ធនាគារ ABA ប្រមូលបានទឹកប្រាក់ ៩.០០០ ដុល្លារអាមេរិកពីអតិថិជនរបស់ខ្លួន ហើយបង្គ្រប់ឲ្យគ្រប់ទឹកប្រាក់ ១៨.០០០ដុល្លារអាមេរិក។ ទឹកប្រាក់ដែលរៃអង្គាសបាននេះត្រូវបានប្រគល់ជូនក្រសួងសុខាភិបាលសម្រាប់ទិញសម្ភារសុខាភិបាលដើម្បីកាត់បន្ថយការរីករាលដាលនៃវីរុស។

បន្ថែមលើនេះ ធនាគារ ABA ចូលភាគទានជាចំនួនទឹកប្រាក់ និងសម្ភារសុខាភិបាលមួយចំនួនដែលមានតម្លៃ ១០.០០០ ដុល្លារអាមេរិក ដើម្បីជួយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត តាមរយៈសមាគមធនាគារនៅកម្ពុជា (ABC) ដើម្បីព្យាបាល និងបង្ការវីរុសកូវីដ-១៩ នៅក្នុងប្រទេស។

ដើម្បីជួយសង្គ្រោះគ្រួសារមានប្រាក់ចំណូលទាបដែលបានបាត់បង់ប្រភពចំណូលចម្បងរបស់ពួកគេដោយសារការបិទបណ្តោះអាសន្ននូវកន្លែងការងាររបស់ពួកគេ ឬកាត់បន្ថយកម្លាំងការងារនោះ ធនាគារ ABA បាននាំនូវស្បៀងអាហារបណ្តោះអាសន្នជូនគ្រួសារចំនួន ៤១៦ ដែលប៉ះពាល់ដោយសារការរីករាលដាលនៃវីរុសកូវីដ-១៩។ គ្រួសារទាំងនោះរស់នៅសហគមន៍ព្រែកអញ្ចាញ ភូមិត្រពាំងអញ្ចាញ នៅជាយរាជធានីភ្នំពេញ ព្រមទាំងនៅភូមិមួយចំនួននៅខេត្តកណ្តាល កំពង់ស្ពឺ និងកំពង់ឆ្នាំង។

# ផ្នែកទី ២

## ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក

| លទ្ធផលសម្រេចបានសំខាន់ៗ | ត្រីមាសទី២ ឆ្នាំ២០២០ | ៣១ ខែធ្នូ ឆ្នាំ២០១៩ |
|---|---:|---:|
| **ផ្នែកសេវាឥណទាន** | | |
| ចំនួនគណនីឥណទាន | ៧៤.០៨២ | ៦៦.៥១៣ |
| ឥណទានដុលសរុប (លានរៀល) | ១២.៨០៨.៣៥៦ | ១១.២៦៥.០៣៧ |
| **ផ្នែកសេវាប្រាក់បញ្ញើ** | | |
| ចំនួនគណនីប្រាក់បញ្ញើ | ១.០៨៣.០៧២ | ៨២៨.៦៥១ |
| ប្រាក់បញ្ញើសរុប (លានរៀល) | ១៥.៦៤៧.១៥២ | ១៣.៨៣៦.០២៥ |
| **ព័ត៌មានទូទៅ** | | |
| ចំនួនសាខាបើកដំណើការ | ៧៧ | ៧៧ |
| ចំនួនបុគ្គលិកសរុប | ៦.៥១៦ | ៦.៤១០ |
| ចំនួនម៉ាស៊ីន អេធីអឹម | ៤៥២ | ៤១៨ |
| ចំនួនម៉ាស៊ីនទូទាត់ | ១.៥២៤ | ១.២១៤ |

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី២ ឆ្នាំ២០២០ | | ត្រីមាសទី២ ឆ្នាំ២០១៩ | |
|---|---|---:|---:|---:|---:|
| | | ចំនួន (លានរៀល) | ភាគរយ(%) | ចំនួន (លានរៀល) | ភាគរយ(%) |
| ១ | ចំណូលពីការប្រាក់ | ៣៣៤.៩៦០ | ៨៨,៧៥ | ២៥២.៥៤៧ | ៨៧,៥៦ |
| ២ | ចំណូលកម្រៃ និងជើងសារ | ៣៩.៩២០ | ១០,៥៨ | ៣៥.០៧៤ | ១២,១៦ |
| ៣ | ចំណូលផ្សេងៗ | ២.៥៥៧ | ០,៦៨ | ៨០១ | ០,២៨ |
| **ចំណូលសរុប** | | **៣៧៧.៤៣៧** | **១០០** | **២៨៨.៤២២** | **១០០** |

# ផ្នែកទី ៣

## របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យ ឡើងវិញដោយសវនករឯករាជ្យ

សូមយោងឧបសម្ពន្ធរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

# ផ្នែកទី ៤

## ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងវិភាគខាងក្រោមនេះ ផ្តោតសំខាន់លើ លទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមកាលបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ដែលត្រូវបានត្រួតពិនិត្យរួចរាល់ដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRS”) និងអនុលោមទៅតាមបទបញ្ញត្តិគណនេយ្យពាក់ព័ន្ធនិងគោលការណ៍ណែនាំនានាដែលចេញដោយ ធនាគារជាតិនៃកម្ពុជា។ ធនាគារធ្វើការពិភាក្សានិងវិភាគទៅលើ សមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និង កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារវឌ្ឍនៈអាស៊ី ចំកាត់។

# ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

## ១. *ការវិភាគចំណូល*

ធនគារ វឌ្ឍនៈអាស៊ីចំកាត់ មានប្រភពចំណូលធំៗចំនួន៣ គឺ ចំណូលមកពីការប្រាក់ ចំណូលកម្រៃ និងជើងសារ និងចំណូលផ្សេងៗ។

- **ចំណូលមកពីការប្រាក់** រួមមាន ចំណូលការប្រាក់ពីការផ្តល់ឥណទានដល់អតិថិជន ចំណូលការប្រាក់ពីការដាក់ប្រាក់បញ្ញើនៅធនាគារ និងចំណូលមកពីមូលប័ត្រវិនិយោគនានា
- **ចំណូលកម្រៃ និងជើងសារ** រួមមាន ការសន្យាឥណទាន ចំណូលពីការផ្ទេរប្រាក់និងវេរប្រាក់ ចំណូលពីប័ណ្ណផ្សេងៗ
- **ចំណូលផ្សេងៗ** រួមមាន ចំណូលពីអត្រាប្តូរប្រាក់ និង ចំណូលផ្សេងៗទៀត។

## ២. *ការវិភាគចំណូលតាមផ្នែក*

| ល.រ | ប្រភពចំណូល | ត្រីមាសទី២ ឆ្នាំ២០២០ | | ត្រីមាសទី២ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន (លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៣៣៤.៩៦០ | ៨៨,៧៥ | ២៥២.៥៤៧ | ៨៧,៥៦ |
| ២ | ចំណូលកម្រៃ និងជើងសារ | ៣៩.៩២០ | ១០,៥៨ | ៣៥.០៧៤ | ១២,១៦ |
| ៣ | ចំណូលផ្សេងៗ | ២.៥៥៧ | ០,៦៨ | ៨០១ | ០,២៨ |
| **ចំណូលសរុប** | | **៣៧៧.៤៣៧** | **១០០** | **២៨៨.៤២២** | **១០០** |

ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ ទទួលបានចំណូលដ៏ធំមកពីការប្រាក់ ដែលមានចំនួន ៨៧,៥៦% នៃប្រាក់ចំណូលសរុបក្នុងត្រីមាសទី២ ឆ្នាំ២០២០ ដែលនៅក្នុងនោះ ៩៧% បានមកពីចំណូលការប្រាក់ពីការផ្តល់ឥណទានដល់អតិថិជន។

## ៣. *ការវិភាគគម្លាតចំណេញដុល*

ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីប្រាក់ចំណេញដុល។ ប៉ុន្តែ ទម្រង់របាយការណ៍នេះអាចបង្ហាញលើប្រាក់ចំណេញពីការប្រាក់សុទ្ធ ដែលទទួលបានមកពីចំណូលការប្រាក់សរុប ដកនឹងចំណាយការប្រាក់ដែលនឹងត្រូវយកមកពិភាក្សានៅក្នុងចំណុច *ការវិភាគចំណេញមុនបង់ពន្ធ*។

## ៤. ការវិភាគប្រាក់ចំណេញមុនបង់ពន្ធ

| សង្ខេបនៃរបាយការណ៍ប្រាក់ចំណេញមុនបង់ពន្ធ | ត្រីមាសទី២ ឆ្នាំ២០២០ (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០១៩ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | ៣៣៤.៩៦០ | ២៥២.៥៤៧ | ៨២.៤១៣ | ៣២,៦៣ |
| ចំណាយលើការប្រាក់ | (៦១.៦៣៨) | (៤៩.២៥៩) | (១២.៣៧៩) | ២៥,១៣ |
| **ចំណូលមកពីការប្រាក់សុទ្ធ** | **២៧៣.៣២២** | **២០៣.២៨៨** | **៧០.០៣៤** | **៣៤,៤៥** |
| ចំណូលកម្រៃ និងជើងសារ | ៣៩.៩២០ | ៣៥.០៧៤ | ៤.៨៤៦ | ១៣,៨២ |
| ចំណាយកម្រៃ និងជើងសារ | (១៣.៣៨៧) | (១២.៨៩០) | (៤៩៧) | ៣,៨៦ |
| **ចំណូលកម្រៃ និងជើងសារសុទ្ធ** | **២៦.៥៣៣** | **២២.១៨៤** | **៤.៣៤៩** | **១៩,៦០** |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២.៥៥៧ | ៨០១ | ១.៧៥៦ | ២១៩,២៣ |
| ចំណាយបុគ្គលិក | (៧៣.០២១) | (៥៩.៤៩៤) | (១៣.៥២៧) | ២២,៧៤ |
| ចំណាយប្រតិបត្តិការ | (២៩.៥៤៣) | (២០.៦៣០) | (៨.៩១៣) | ៤៣,២០ |
| ចំណាយរំលស់ | (២០.៥៨៤) | (១៤.៣៣៣) | (៦.២៥១) | ៤៣,៦១ |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | **១៧៩.២៦៤** | **១៣១.៨១៦** | **៤៧.៤៤៨** | **៣៦,០០** |
| ការខាតបង់លើឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ | (១១.៥៣៣) | (៤.២១០) | (៧.៣២៣) | ១៧៣,៩៤ |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **១៦៧.៧៣១** | **១២៧.៦០៦** | **៤០.១២៥** | **៣១,៤៤** |

ក្នុងត្រីមាសទី២ ឆ្នាំ២០២០ ប្រាក់ចំណេញមុនបង់ពន្ធមានចំនួន ១៦៧.៧៣១លានរៀល ដែលបានកើនឡើង ៣១,៤៤% ស្មើនឹង ៤០.១២៥លានរៀល ប្រៀបធៀបទៅនឹងត្រីមាសទី២ ឆ្នាំ២០១៩ ។ ការកើនឡើងនៃប្រាក់ចំណេញនេះ គឺបណ្តាលមកពីការកើនឡើង ៣២,៦៣%នៃចំណូលមកពីការប្រាក់ និង ចំណូលកម្រៃ និងជើងសារ ១៣,៨២% បើប្រៀបធៀបទៅនឹងត្រីមាសទី២ ឆ្នាំ២០១៩។

### ៥. ការវិភាគប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ប្រាក់ចំណេញសុទ្ធ | ត្រីមាសទី២ ឆ្នាំ២០២០ (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០១៩ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ១៦៧.៧៣១ | ១២៧.៦០៦ | ៤០.១២៥ | ៣១,៤៤ |
| ចំណាយពន្ធលើប្រាក់ចំណូល | (៣៦.៩០១) | (២៦.១១៩) | (១០.៧៨២) | ៤១,២៨ |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | **១៣០.៨៣០** | **១០១.៤៨៧** | **២៩.៣៤៣** | **២៨,៩១** |

ក្នុងត្រីមាសទី២ ឆ្នាំ២០២០ ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ បានទទួលប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធ ចំនួន ១៣០.៨៣០លានរៀល ដែលបានកើនឡើងចំនួន ២៨,៩១% បើប្រៀបធៀបទៅនឹងត្រីមាសទី២ ឆ្នាំ២០១៩ បង្ហាញអំពីការលូតលាស់យ៉ាងខ្លាំងរបស់ធនាគារ។ ជាលទ្ធផល ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ ទទួលបានអនុបាតចំណេញធៀបនឹងមូលធនចំនួន ៥,០៦% និង អនុបាតចំណេញធៀបនឹងទ្រព្យសកម្មចំនួន ០,៧០% គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

### ៦. ការវិភាគចំណូលលម្អិតសរុប

| សង្ខេបនៃរបាយការណ៍ចំណូលលម្អិតសរុប | ត្រីមាសទី២ ឆ្នាំ២០២០ (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០១៩ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធក្នុងគ្រា | ១៣០.៨៣០ | ១០១.៤៨៧ | ២៩.៣៤២ | ២៨,៩១ |
| ចំណូលលម្អិតផ្សេងៗ | ៦.៦១១ | ៨.៣៨៤ | (១.៧៧៣) | (២១,១៥) |
| **ចំណូលលម្អិតសរុប** | **១៣៧.៤៤១** | **១០៩.៨៧១** | **២៧.៥៧០** | **២៥,០៩** |

### ៧. ការវិភាគកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ គណៈគ្រប់គ្រងទទួលស្គាល់ថា ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ មិនមានកត្តា សំខាន់ៗ និងនិន្នាការសំខាន់ៗណាដែលអាចប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់ ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ ឡើយ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ ចាត់ទុកចំណុចខាងក្រោមជាកត្តាជោគជ័យដែលនាំមកនូវផលចំណេញ៖

- កំណើនមូលនិធិ ដោយសារតម្រូវការបញ្ញើសម្រាប់ធនាគារ រួមជាមួយផលិតផល និងសេវាកម្មប្រតិបត្តិការផ្សេងៗទៀត
- កំណើនផលបត្រឥណទាន ដោយសារតម្រូវការខ្ពស់នៅទីផ្សារ មកលើផលិតផលកម្ចីរបស់ធនាគារ ជាពិសេស វិស័យ MSME។

កត្តាទាំងពីរនេះ ត្រូវបានរាប់បញ្ចូលជាមួយការបន្តអភិវឌ្ឍលើប្រព័ន្ធឌីជីថលរបស់ធនាគារ ដែលផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុដ៏ទំនើប និងប្រកបដោយនវានុវត្ត។

កម្មវិធីធនាគារតាមទូរស័ព្ទដៃ ABA Mobile ទទួលបានការពង្រឹងសំខាន់ជាច្រើននៅក្នុងត្រីមាសទីពីរ។ ឥឡូវនេះ អ្នកប្រើប្រាស់កម្មវិធី ABA Mobile អាចផ្ញើប្រាក់ទៅធនាគារក្នុងស្រុកមុខងារគ្រប់គ្រងកាតធនាគារ និងមុខងារផ្ញើប្រាក់ភ្លាមៗជាមួយ Visa Direct ទៅកាន់កាត Visa ណាមួយនៅកម្ពុជា និងកាត Visa ដែលចេញដោយធនាគារនៅប្រទេសថៃ វៀតណាម ឡាវ ភូមា ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូនេស៊ី និងហ្វីលីពីន។

ធនាគារក៏បានវិនិយោគដ៏សំខាន់នៅក្នុងការពង្រឹងទីតាំងស្វ័យសេវាធនាគារ ដោយធ្វើការដំណើងបន្ថែមនូវម៉ាស៊ីនដាក់ ATM ម៉ាស៊ីនដាក់/ដកប្រាក់ ម៉ាស៊ីនដាក់ប្រាក់ ម៉ាស៊ីនទូទាត់ POS និងការពង្រីកបណ្តាញទូទាត់តាមកូដ QR របស់ខ្លួន។

### ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ ABA ប្រតិបត្តិការក្នុងឧស្សាហកម្មសេវាកម្ម ដូច្នេះ ការឡើងចុះថ្លៃវត្ថុធាតុដើមមិនប៉ះពាល់ដល់ធនាគារឡើយ។

### ៣. ការវិភាគលើពន្ធ

ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារនៃប្រទេសកម្ពុជា ដូច្នេះ ធនាគារ មានកាតព្វកិច្ចក្នុងការបង់ពន្ធ ដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។

ការបង់ពន្ធនានាជូនអគ្គនាយកដ្ឋានពន្ធដារ ក៏ជាការរួមចំណែកដល់សង្គម និងកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាផងដែរ។ សម្រាប់អនុលោមភាពល្អលើកាតព្វកិច្ចពន្ធដារ ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ ទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ “មាស” ពីអគ្គនាយកដ្ឋានពន្ធដារ នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩ ដែលមានសុពលភាព ២ឆ្នាំសម្រាប់ឆ្នាំជាប់ពន្ធ ២០១៩ និង ២០២០។

### ៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ គណៈគ្រប់គ្រងទទួលស្គាល់ថាធនាគារ វឌ្ឍនៈអាស៊ីចំកាត់ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និង មិនប្រក្រតីនោះទេ។

ទន្ទឹមនឹងការរីករាលដាលនៃវីរុសកូវីដ-១៩ សេដ្ឋកិច្ចពិភពលោក មានការធ្លាក់ចុះគួរឲ្យកត់សម្គាល់។ ស្របពេលជាមួយគ្នានេះ គណៈគ្រប់គ្រងបានវាយតម្លៃពីផលប៉ះពាល់របស់វីរុសកូវីដ-១៩ មកលើធនាគារ ហើយសន្និដ្ឋានថាមិនមានផលប៉ះពាល់ជាសារវន្តមកលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារទេ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នាត្រីមត្រីមាសទី២ ឆ្នាំ២០២០ ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ ទទួលបានកំណត់ត្រាកំណើននៃចំណូលគួរឲ្យកត់សម្គាល់ ដោយធានាបាននូវចំណូលការប្រាក់សុទ្ធសរុប ២៧៣,៣ ប៊ីលានរៀល ដែលស្មើនឹងកំណើន ៣៤,៥៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។ ចំណេញប្រតិបត្តិការមានចំនួនសរុប ១៧៩,២ ប៊ីលានរៀល ដែលខ្ពស់ជាងត្រីមាសទី២ ឆ្នាំ២០១៩ ប្រមាណ ៣៦%។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ ប្រកាន់ភ្ជាប់នូវយុទ្ធសាស្ត្រមិនបណ្តោយឲ្យទទួលរងហានិភ័យពីស្ថានភាពរូបិយប័ណ្ណបរទេសចំហច្រើន។ ស្ថានភាពចំហនៃរូបិយប័ណ្ណបរទេស ត្រូវបានត្រួតពិនិត្យ និងចាត់ចែងជាប្រចាំ ដោយធៀបនឹងតម្រូវការប្រតិបត្តិការរូបិយប័ណ្ណរបស់អតិថិជន និងការគ្រប់គ្រងតារាងសមតុល្យរបស់ធនាគារ ដោយធានាបាននូវនិរន្តរភាពនៃប្រាក់ចំណេញជូនធនាគារ។

ពាក់ព័ន្ធនឹងអត្រាការប្រាក់ ធនាគាររក្សាបាននូវគោលនយោបាយអត្រាការប្រាក់ថេរស្រាប់ប្រាក់បញ្ញើ និងកម្ចីរបស់ ខ្លួន។ ដូច្នេះ ធនាគារមិនមានការប្រែប្រួលជាសារវន្តណាមួយពាក់ពន្ធនឹងអត្រាការប្រាក់ក្នុងអំឡុងពេលរបាយការណ៍នេះឡើយ។ ឥទ្ធិពលនៃតម្លៃទំនិញ មិនបង្កផលប៉ះពាល់ដល់ធនាគារឡើយ។

## ង. ផលប៉ះពាល់នៃអតិផរណា

អត្រាអតិផរណារួមជាមធ្យមនៅកម្ពុជាគិតត្រឹមឆមាសទី១ ឆ្នាំ២០២០ មានកម្រិតត្រឹម ២,៥% យោងតាមរបាយការណ៍ប្រចាំឆមាសទី១ចេញដោយធនាគារជាតិ នៃកម្ពុជា។ ដូច្នេះ នៅក្នុងត្រីមាសទី២ ឆ្នាំ២០២០ មិនមានផលប៉ះពាល់ជាសារវន្តនៃអតិផរណាមកលើការចំណាយប្រតិបត្តិការរបស់ធនាគារ ABA ឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

នៅក្នុងរយៈពេលនៃរបាយការណ៍ សេដ្ឋកិច្ចកម្ពុជាបន្តរងផលប៉ះពាល់នៃការរីករាលដាលនៃវីរុសកូវីដ-១៩។ វិស័យទេសចរណ៍ វិស័យកម្មន្តសាល វិស័យសំណង់ និងវិស័យសំខាន់ៗសម្រាប់សេដ្ឋកិច្ចជាច្រើនទៀត ទទួលរងផលប៉ះពាល់ខ្លាំង។

ដើម្បីកាត់បន្ថយផលប៉ះពាល់លើសង្គម និងសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញជាបន្តបន្ទាប់នូវវិធានការនានាដើម្បីគាំទ្រដល់វិស័យអាទិភាពនានា។ ជាពិសេស ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីថ្លែងការណ៍ពន្យារពេលការអនុវត្តទ្រនាប់ដើមទុនឧនស៊ើរវេសិន បន្ថយអត្រាការប្រាក់លើលក្ខខណ្ឌតម្រូវប្រាក់បម្រុង និងអត្រាការប្រាក់លើប្រាក់កម្ចី និងបន្តផ្តល់កម្ចីរយៈពេលខ្លីដល់គ្រឹះស្ថានហិរញ្ញវត្ថុនានា ដើម្បីធានាស្ថេរភាពដែលឆ្លើយតបនឹងតម្រូវការផ្នែកសេដ្ឋកិច្ច។

នៅខែមីនា ធនាគារជាតិនៃកម្ពុជាបានចេញសារាចរទៅកាន់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ឲ្យរៀបចំកម្ចីឡើងវិញដើម្បីរក្សាស្ថេរភាពហិរញ្ញវត្ថុគាំទ្រសកម្មភាពសេដ្ឋកិច្ច និងបន្ធូរបន្ថយបន្ទុករបស់អតិថិជនកម្ចី ដែលមានការពិបាកក្នុងការបង់សងកម្ចីអំឡុងពេលការរីករាលដាលនៃវីរុសកូវីដ-១៩។ សារាចរនេះតម្រូវឲ្យគ្រឹះស្ថានហិរញ្ញវត្ថុបង្កើតគោលនយោបាយ និងនីតិវិធីអំពីការរៀបចំកម្ចីឡើងវិញ និងយកចិត្តទុកដាក់ជិតដិតចំពោះអតិថិជន ជាពិសេសអតិថិជនក្នុងវិស័យទេសចរណ៍ វិស័យកាត់ដេរ វិស័យសំណង់ និងវិស័យដឹកជញ្ជូន។

លើសពីនេះ គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ឆ្នាំ២០២០ (SCFS) ត្រូវបានដាក់ឲ្យដំណើរការ។ គម្រោងនេះជាគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងគោលបំណងផ្តល់ឥណទានមានការប្រាក់ទាប ដើម្បីគាំទ្រសហគ្រាសធុនតូច និងមធ្យម។ ក្រោមគម្រោងសហហិរញ្ញប្បទាននេះ គ្រឹះស្ថានហិរញ្ញវត្ថុដែលចូលរួម អាចផ្តល់កម្ចីសម្រាប់ទុនបង្វិល និងចំណាយមូលធន ជាមួយអត្រាការប្រាក់ពិសេស ៧% ក្នុងមួយឆ្នាំ ជាមួយរយៈពេលឥណទានរហូតដល់ ៧ឆ្នាំ។

វិធានការទាំងនេះ ព្រមជាមួយគំនិតផ្តួចផ្តើមផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជា មានគោលបំណងគាំទ្រសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុជាពិសេស។

ជាលទ្ធផល គណៈគ្រប់គ្រងធនាគារបានវាយតម្លៃស្ថានភាពបច្ចុប្បន្ន និងសន្និដ្ឋានថា មានផលប៉ះពាល់តិចតួចមកលើលទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ នៅក្នុងត្រីមាសទីពីរ ឆ្នាំ២០២០។

ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ
ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០
ហត្ថលេខា និងត្រា

លោក **Madi Akmambet**
អភិបាលប្រតិបត្តិ

ជ. លោក **Dominic Jacques**
អភិបាលមិនប្រតិបត្តិ

លោក **Madi Akmambet**
អភិបាលប្រតិបត្តិ

ABA BANK

NATIONAL BANK OF CANADA GROUP

អគារលេខ១៤១, ១៤៦, ១៤៨ និង១៤៨ អា បេ សេ ដេ វិថីព្រះសីហនុ
និងអគារលេខ ១៥ និង ១៥៣ អា បេ សេ ផ្លូវលេខ ២៧៨ សង្កាត់
បឹងកេងកង ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

(+៨៥៥) ២៣ ២២៥ ៣៣៣ | ទូរសារ: (+៨៥៥) ២៣ ២១៦ ៣៣៣
info@ababank.com | www.ababank.com